ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ: ១៤៣/...១៩៨
ដ០

# របាយការណ៍ត្រីមាសទី២
# ស្តីពី
# ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ
# និងទិសដៅត្រីមាសទី៣ ឆ្នាំ២០២០

## I. ស្ថានភាពទូទៅ

ក្នុងរយៈពេលត្រីមាសទី២ ឆ្នាំ២០២០ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស របស់ក្រសួង ស្ថាប័ន រាជធានី ខេត្ត បានបន្តសកម្មភាព របស់ខ្លួនទៅតាមទិសដៅគ្រោងទុក បើទោះបីជាបាន និងកំពុងតែប្រឈម នឹងសភាពការណ៍វិវត្តថ្មី ដែលមិនអាចប៉ាន់ស្មានបាន ពាក់ព័ន្ធនឹងស្ថានភាពប្រែប្រួលនៃសេដ្ឋកិច្ចពិភពលោក និង បន្ថែមដោយវិបត្តិនៃការរាតត្បាតដោយជំងឺខូវីដ-១៩ ។

ក្រសួងស្ថាប័ន និងរាជធានី ខេត្ត បានប្តូរទិសដៅការងារ ផ្តោតការយកចិត្តទុកដាក់បន្ថែម ទៅលើបញ្ហាវិបត្តិ ខូវីដ-១៩ ដែលជាភាពប្រឈមថ្មី និងដែលជះឥទ្ធិពលដល់ការអនុវត្តសកម្មភាពគ្រប់វិស័យ ធ្វើឲ្យរាំងស្ទះដោយអន្លើ និង ត្រូវបន្ថែមភារកិច្ច ក្នុងការដោះស្រាយទប់ស្កាត់ផលប៉ះពាល់ លើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ជាពិសេស អ្នកដែល វិលត្រឡប់ពីប្រទេសក្រៅ ដែលមានចំនួន ច្រើនលើសលប់ និងភាគច្រើន ជាអ្នកដែលខ្វះលទ្ធភាព ក្នុងការទ្រទ្រង់ ជីវភាព ហើយងាយរងគ្រោះ។ ការជួយសង្គ្រោះពលករដែលវិលត្រឡប់មកពីក្រៅប្រទេស គឺជាកិច្ចការចាំបាច់ ដើម្បី បង្ការទប់ស្កាត់ ការនាំចូលជំងឺខូវីដ ១៩ ទៅក្នុងសហគមន៍ និងការដោះស្រាយភាពប្រឈមក្នុងពេលធ្វើសមាហរណកម្ម ទៅក្នុងសហគមន៍ ព្រមទាំងទប់ស្កាត់ការចាញ់បោកមេខ្យល់ក្នុងការនាំពលករត្រឡប់ទៅប្រទេសគោលដៅវិញ ក្នុងស្ថាន ភាពដែលមានការរឹតបន្តឹងពីប្រទេសគោលដៅ ដើម្បីការពារជំងឺរាតត្បាត និងវិបត្តិសេដ្ឋកិច្ចដែលកើតមានទូទាំងពិភព លោក ដែលធ្វើឲ្យពលករខាតបង់រឹតតែធ្ងន់ធ្ងរ និងធ្លាក់ទៅក្នុងរលកថ្មីនៃអំពើជួញដូរមនុស្ស ។

អាជ្ញាធរ សមត្ថកិច្ច និងលេខាធិការដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ និងអង្គការដៃគូ បានធ្វើសកម្មភាពយ៉ាងមមាញឹក ប្រចាំការនៅតាមព្រំដែនទទួលសង្គ្រោះពលករ ដែលវិលត្រឡប់តាមច្រកមិនផ្លូវការ ទាំងយប់ទាំងថ្ងៃ ពិនិត្យកម្តៅ និងផ្តល់សេវាសុខភាព អនុវត្តគោលការណ៍ចត្តាឡីស័កតាមវិធានសុខាភិបាល ផ្តល់ អាហារ ត្រៀមមធ្យោបាយដឹកជញ្ជូន ឱ្យបានដល់លំនៅដ្ឋាន និងបន្តតាមដានស្ថានភាពសុខភាព ជីវភាព និងផ្តល់សេវា តាមតម្រូវការផ្សេងៗ និងបន្តតាមដានស្ថានភាព នៅពេលធ្វើសមាហរណកម្មទៅក្នុងសហគមន៍ដែលពួកគាត់រស់នៅ ។ លើសពីនេះទៅទៀត វិធានការអប់រំ បង្ការទប់ស្កាត់សកម្មភាពវិលត្រឡប់ទៅប្រទេសថៃវិញ ក្នុងអំឡុងពេលដែល មានការរឹតបន្តឹង ពីប្រទេសគោលដៅក្នុងវិធានការទប់ស្កាត់វិបត្តិខូវីដ ១៩ និងដោះស្រាយវិបត្តិសេដ្ឋកិច្ច ការបង្កើនការ ស៊ើបអង្កេតរកមេខ្យល់ជួញដូរមនុស្សក្នុងដំណាក់កាលនេះ ការផ្តល់សេវាជួយជនរងគ្រោះ និងជនងាយរងគ្រោះ ត្រូវបាន ធ្វើឡើង កាន់តែសកម្ម ។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលកើតមានខាងលើនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរ មនុស្ស ដែលមានអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាសេនាធិការ បានបង្កើនការយកចិត្តទុកដាក់ សម្របសម្រួល

ពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័ន ជាសមាជិក និងជំរុញសកម្មភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាជធានី-ខេត្ត មន្ទីរ អង្គភាព និងដៃគូជាតិ អន្តរជាតិ ក៏ដូចជាសមត្ថកិច្ចនៃប្រទេសពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាព និងកិច្ចប្រតិបត្តិការដើម្បីដោះស្រាយបញ្ហារួមគ្នា ដោយទទួលបានលទ្ធផល ដូចខាងក្រោម៖

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការងារ ច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ការអនុវត្តច្បាប់ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ

#### ក.១. ការកសាងច្បាប់

- ក្រសួងយុត្តិធម៌ និងក្រសួងកិច្ចការនារី បានដឹកនាំធ្វើសេចក្តីព្រាងច្បាប់ ស្តីពី"**ការពពោះជំនួស**"។
- ក្រសួងយុត្តិធម៌
  - បានចេញសេចក្តីសម្រេចច្បាប់ ស្តីពី"**ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ**" (MLA) នៅខែមិថុនា ឆ្នាំ២០២០។
  - បានរៀបចំសេចក្តីព្រាងច្បាប់ ស្តីពី "**ការប្រឆាំងអំពើរត់ពន្ធមនុស្ស**"។

#### ក.២. សន្ធិសញ្ញា

- ក្រសួងយុត្តិធម៌
  - បានកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសឡាវ បារាំង និងប្រទេសកូរ៉េខាងត្បូង ស្តីពី"ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ"
  - បានកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសអង់គ្លេស ប៉េរូ និងប្រទេសឡាវ ស្តីពី "ការបញ្ជូនទណ្ឌិត"។

#### ក.៣. គោលនយោបាយ និងអនុស្សរណៈនៃការយោគយល់គ្នា

- ក្រសួងទេសចរណ៍ ត្រៀមចុះអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការអនុវត្តគម្រោងកុមារភាពជាមួយអង្គការ Friends International។
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានប្រជុំថ្នាក់មន្ត្រីបច្ចេកទេសលើកទី៤ និងថ្នាក់រដ្ឋមន្ត្រីលើកទី២ ដើម្បីអនុវត្តអនុស្សរណៈនៃការយោគយល់គ្នារវាង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃប្រទេសម៉ាឡេស៊ី ស្តីពី "**ការជ្រើសរើស ការបញ្ជូន និងការគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅប្រទេសម៉ាឡេស៊ី**"។

#### ក.៤. លិខិតបទដ្ឋានគតិយុត្ត

- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ៖ បានចុះហត្ថលេខាលើលិខិតបទដ្ឋានគតិយុត្តិ "សម្រាប់អនុវត្តលក្ខខណ្ឌការងារកម្មករការងារផ្ទះ" ដោយឯកឧត្តម **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖ បានធ្វើសេចក្តីព្រៀងរៀបចំអនុក្រឹត្យ ស្តីពីរបបគោលនយោបាយសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចគ្រប់ទម្រង់ផ្សេងៗទៀត ដែលស្នាក់នៅមណ្ឌលសំចតរបស់រដ្ឋ និងរស់នៅតាមសហគមន៍។

### ខ. ការបង្ការ ទប់ស្កាត់

#### ខ.១. តាមរយៈការលើកកម្ពស់ការយល់ដឹង

**ខ.១.១. ការផ្សព្វផ្សាយជាសាធារណៈ**

| ល.រ | ផ្សព្វផ្សាយតាមរយៈ | ចំនួនលើក | ចំនួនអ្នកចូលរួម |
|---|---|---|---|
| ១ | វេទិកាសាធារណៈ និងភូមិ-ឃុំមានសុវត្ថិភាព | ២១.២៧៥ លើក | ៨៨៨.២៧៣ នាក់ |
| ២ | អង្គការដៃគូនានា | ៩៩ លើក | ១២.២៣៨ នាក់ |
| សរុប | | ២១.៣៧៤ លើក | ៩០០.៥១១នាក់ |

**ខ.១.២. វេទិកាសាធារណៈ និងភូមិ ឃុំសុវត្ថិភាព**

នៅក្នុងត្រីមាសទី២ ឆ្នាំ២០២០នេះ ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អាជ្ញាធរ មន្ទីរពាក់ព័ន្ធ បានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមរយៈកិច្ចប្រជុំ វេទិកាសាធារណៈ ការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ មានសុវត្ថិភាព" និងកម្មវិធីផ្សេងៗ ដល់មន្ត្រីរាជការ សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ សាសនិកជន និងប្រជាពលរដ្ឋ សរុបចំនួន ២១.២៧៥លើក មានអ្នកចូលរួមសរុបចំនួន ៨៨៨.២៧៣នាក់ (ធៀបនឹងត្រីមាសទី១ ឆ្នាំ២០២០ មានចំនួន ១.៦៧៩.៥៧៨នាក់ គឺមានការថយចុះចំនួន ៧៩១.៣០៥នាក់) ស្មើនឹង៤៧,១១% ក្នុងនោះស្ត្រីចំនួន ៤៨៦.០២០នាក់ ដូចមានតារាងលម្អិតខាងក្រោម៖

<u>**តារាងទិន្នន័យការអប់រំផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ និងវេទិកាសាធារណៈ**</u>

| ល.រ | ក្រសួង ស្ថាប័ន | ផ្សព្វផ្សាយ | | | វេទិកាសាធារណៈ | | |
|---|---|---|---|---|---|---|---|
| | រាជធានី-ខេត្ត | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី |
| ក្រសួង ស្ថាប័ន | | | | | | | |
| ១ | អគ្គស្នងការដ្ឋាននគរបាលជាតិ | ៨៧៦ | ២៦.៤៦១ | ១៥.១៧២ | ៨៩ | ២.៧៦៣ | ១.២៤៨ |
| | សរុប ក្រសួង ស្ថាប័ន | | | | | | |
| រាជធានី-ខេត្ត | | | | | | | |
| ១ | រាជធានីភ្នំពេញ | | | | | | |
| ២ | ខេត្តកណ្តាល | ២.០២០ | ១២៦.២៩៧ | ៧៥.០៤០ | ២.៦០៨ | ១០៨.៥៨៦ | ៤៦.៦០៨ |
| ៣ | ខេត្តបាត់ដំបង | ៣.៣៧៨ | ១៣០.៦៨៦ | ៦៧.៥៣៥ | ១.២៤០ | ៣៤.០២៩ | ១៨.២១៦ |
| ៤ | ខេត្តពោធិ៍សាត់ | ៦៩៤ | ៤១.៥៥៤ | ២៦.៧៥៨ | ២២៥ | ៦.៦២៩ | ៩.៦៣៥ |
| ៥ | ខេត្តសៀមរាប | ១.២៧០ | ៤៩.៣៦១ | ២៩.៦៩៤ | ១៥០ | ៤.៥២៩ | ២.៥១៨ |
| ៦ | ខេត្តកំពង់ឆ្នាំង | ១.២៨៦ | ៤៧.៤៣២ | ២៥.៣៧០ | ៤៦៤ | ១៦.១៤៤ | ៨.៦០២ |
| ៧ | ខេត្តកំពង់ចាម | ២.៤៧៣ | ៨៤.៣១០ | ៤៦.៧៤៣ | ១.៣៨៣ | ៣៩.១៩៨ | ២០.១២៨ |
| ៨ | ខេត្តព្រះសីហនុ | ៥៧ | ៤.៤៤៨ | ៤.២៨៤ | ៥២ | ១.៧០៤ | ៨៣៦ |
| ៩ | ខេត្តព្រះវិហារ | ៤០ | ២.៤៨៧ | ១.៤៩៨ | ៥៣ | ១.៥៦២ | ៩៤០ |
| ១០ | ខេត្តស្វាយរៀង | ១៥៩ | ៤.១២៦ | ២.១៦២ | ៨៤៧ | ២៦៩៦៨ | ១៤.៥៩៦ |
| ១១ | ខេត្តប៉ៃលិន | ៣៧២ | ៦.២៥៤ | ២.៨០៨ | ១២៧ | ៤.១៣៣ | ២.៦៨៥ |
| ១២ | ខេត្តកោះកុង | ២ | ២១ | ១៤ | ៣០៧ | ៥.៤០៦ | ២.៧១៨ |
| ១៣ | ខេត្តកំពត | | | | | | |
| ១៤ | ខេត្តកំពង់ធំ | | | | | | |
| ១៥ | ខេត្តតាកែវ | ៥៧៥ | ២៩.៧៣៦ | ១៥.១៦៩ | ១៨៦ | ៧.២៨៨ | ៣.៤៤៩ |
| ១៦ | ខេត្តក្រចេះ | ៧៤ | ២.០៩៥ | ១.១៦០ | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១៧ | ខេត្តកែប | | | | ១៦ | ១.២៤០ | ១.១៣៦ |
| ១៨ | ខេត្តកំពង់ស្ពឺ | ១៦៥ | ៧.០១៣ | ៣.៥៩០ | ៣៧ | ៣.២៤៩ | ១.៧៧០ |
| ១៩ | ខេត្តស្ទឹងត្រែង | | | | ២៩ | ៧៤៤ | ៤០៥ |
| ២០ | ខេត្តរតនគិរី | | | | | | |
| ២១ | ខេត្តព្រៃវែង | | | | | | |
| ២២ | ខេត្តត្បូងឃ្មុំ | ១១ | ២៧.០៨៥ | ១៥.៦៩៧ | ៧ | ២៤.៦៧២ | ១៧.៨០៨ |
| ២៣ | ខេត្តបន្ទាយមានជ័យ | ១ | ១៩ | | | | |
| ២៤ | ខេត្តឧត្តរមានជ័យ | ៣ | ៦៣ | ២៨ | | | |
| ២៥ | ខេត្តមណ្ឌលគិរី | | | | | | |
| សរុប រាជធានី-ខេត្ត | | ១២.៥៧៩ | ៥៧២.៩៦៨ | ៣១៧.៥៥០ | ៧.៧៣១ | ២៨៦.០៨១ | ១៥២.០៥០ |
| សរុបរួម<br>ក្រសួង ស្ថាប័ន និងរាជធានី-ខេត្ត | | ចំនួន<br>២១.២៧៥ លើក | | អ្នកចូលរួមសរុប<br>៨៨៨.២៧៣ នាក់ | | ស្ត្រីចំនួន<br>៤៨៦.០២០ នាក់ | |

## ខ.១.៣. ការផ្សព្វផ្សាយតាមរយៈកម្មវិធីផ្សេងៗ

▪ អង្គការដៃគូ

*តារាងទិន្នន័យនៃការអប់រំផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ របស់អង្គការដៃគូនានា តាមបណ្ដារាជធានី-ខេត្ត*

| រាជធានី-ខេត្ត | *សកម្មភាព* | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី |
|---|---|---|---|---|
| ខេត្តសៀមរាប<br>អង្គការបន្ទាយស្រី | - បានសហការជាមួយអាជ្ញាធរស្រុកអង្គរជុំ ប្រជុំផ្សព្វផ្សាយ និងចងក្រងបណ្ដាញសុវត្ថិភាពសហគមន៍ ស្ដីពីការធ្វើចំណាកស្រុកប្រកបដោយ សុវត្ថិភាព។ | ០៤ | ៨១ | ៥៨ |
| ខេត្តសៀមរាប<br>អង្គការវីវើល/ជីវីស៊ី | - បានសហការជាមួយមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ប្រជុំផ្សព្វផ្សាយ ស្ដីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងសិទ្ធិពលករ ចំណាកស្រុកក្នុងប្រទេសថៃ ដល់អាជ្ញាធរស្រុក ឃុំ ភូមិ។ | ០៧ | ៨៧១ | ៦៦៨ |
| (ខេត្តសៀមរាប)<br>មូលនិធិអេ២១ | - បានធ្វើការផ្សព្វផ្សាយ ស្ដីពីច្បាប់ពាក់ព័ន្ធនឹងការប្រឆាំងការជួញដូរមនុស្ស ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងសិទ្ធិកុមារ ដល់ប្រជាពលរដ្ឋ សិស្ស និស្សិត។ | ៧៣ | ៨.៩៥៤ | ៣.៣០៩ |
| ខេត្តសៀមរាប<br>ដៃនដីមនុស្ស-ហូឡង់ដ៍ | - បានអនុវត្តសកម្មភាពបង្ការ ទប់ស្កាត់ការកេងប្រវ័ញ្ចកុមារនៅសហគមន៍ ដោយផ្សព្វផ្សាយដល់ក្រុមយុវជន គ្រួសារកុមារ និងប្រជាពលរដ្ឋ។ | ០៥ | ៥៤ | ២២ |
| ខេត្តស្វាយរៀង<br>អង្គការឆាលហ្វាន<br>អង្គការ CCPCR | - បានប្រជុំប្រឹក្សាយោបល់ និងផ្សព្វផ្សាយអំពីបញ្ហាប្រឈម និងភាពងាយរងគ្រោះដោយការធ្វើចំណាកស្រុកគ្មានសុវត្ថិភាព ការរំលោភបំពាន ការកេងប្រវ័ញ្ច និងកិច្ចការពារកុមារ នៅឃុំក្រសាំង និងឃុំអណ្ដូងត្របែក ស្រុករមាសហែក។ | ០៩ | ៣៦៦ | ១៨៤ |
| ខេត្តបន្ទាយមានជ័យ<br>អង្គការសាម៉ារីតាន់ភឺស | - បានអប់រំផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងចែកខិត្តប័ណ្ណផ្សព្វផ្សាយស្ដីពីការធ្វើចំណាកស្រុក | ០១ | ១.៩១២ | ៥៤០ |
| សរុប | | ៩៩ លើក | ១២.២៣៨ នាក់ | ៤.៧៧១ នាក់ |

## ខ.១.៤ ការផ្សព្វផ្សាយ តាមរយៈឧបករណ៍ផ្សព្វផ្សាយ (IEC)

- ខេត្តបន្ទាយមានជ័យ ៖

- អង្គការសាម៉ារីតាន់ភឺស បានចែកខិតប័ណ្ណផ្សព្វផ្សាយ ស្តីពីការធ្វើចំណាកស្រុក ដល់ជនចំណាកស្រុកចំនួន ៤.៧៦៦នាក់ (ស្រី ២.០៧៣នាក់)។
- អង្គការ IOM បានចែកខិតប័ណ្ណផ្សព្វផ្សាយ របស់អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ដល់ជនចំណាកស្រុកចំនួន ១.៩០៦នាក់ (ស្រី ៩៦១នាក់)។

**ខ.១.៤. ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និង ប្រព័ន្ធអេឡិកត្រូនិក**

- ខេត្តសៀមរាបៈ មន្ទីរព័ត៌មានខេត្ត បានធ្វើការផ្សព្វផ្សាយអប់រំ នៅក្នុងកម្មវិធីវិទ្យុ FM ជាតិនគរភ្នំ ១០៣ MHz និងទូរទស្សន៍ជាតិខេត្តសៀមរាប អំពីអំពើហិង្សាក្នុងគ្រួសារ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ពិសេសការស្វែងរកជំនួយពីអាជ្ញាធរ និងអង្គការសង្គមស៊ីវិល និងការផ្សព្វផ្សាយអំពីស្ពតអប់រំ ស្តីពីគ្រឿងញៀន ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងពាក់ព័ន្ធការជួញដូរមនុស្ស សរុបចំនួន ១២៨លើក (ផ្សាយផ្ទាល់ ៣២លើក និងចាក់ផ្សាយឡើងវិញ ៩៦លើក)។
- ខេត្តតាកែវៈ មន្ទីរព័ត៌មានខេត្ត បានផ្សព្វផ្សាយច្បាប់នានាពាក់ព័ន្ធ នឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមរយៈវិទ្យុគោគ្គក សរុបចំនួន ៣០អត្ថបទ និង ១១៤លើក។
- ខេត្តមណ្ឌលគិរីៈ មន្ទីរធម្មការ និងសាសនាខេត្ត បានផ្សព្វផ្សាយតាមរយៈវិទ្យុជាតិ FM 97MHz ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ក្នុងកម្មវិធី "ព្រះពុទ្ធសាសនា ផ្សាភ្ជាប់សង្គម" ចំនួន ៦០លើក។

**ខ.១.៥. ការចូលរួមជាវាគ្មិន ក្នុងកម្មវិធីនានា**

- ថ្នាក់ក្រោមជាតិ

- ខេត្តបាត់ដំបងៈ បានចូលរួមជាវាគ្មិន ក្នុងកម្មវិធីនៃវិទ្យុខេមរា FM91MHz របស់គម្រោង "នៅក៏មានសុវត្ថិភាព ចំណាកស្រុកក៏មានសុវត្ថិភាព" នៃអង្គការសាម៉ារីតាន់ភឺសសង្គ្រោះអន្តរជាតិ ចំនួន ០២លើក។
- ខេត្តកំពង់ចាមៈ តំណាងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអភិបាលរងស្រុកកំពង់សៀម បានចូលរួមជាវាគ្មិន តាមរយៈវិទ្យុ លើប្រធានបទ ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព។
- ខេត្តសៀមរាបៈ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចូលរួមជាវាគ្មិន នៅវិទ្យុជាតិនគរភ្នំ ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងច្បាប់ស្តីពីការងារ ចំនួន ០១លើក។

## ខ.២. ការបង្ការ ទប់ស្កាត់តាមវិធានការជំនាញ

**ខ.២.១. ការគ្រប់គ្រងស្ថិតិៈ បច្ចុប្បន្នភាពចំណាកស្រុក**

- អគ្គស្នងការដ្ឋាននគរបាលជាតិ

- ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានធ្វើបច្ចុប្បន្នភាពទិន្នន័យ ចំពោះពលករចំណាកស្រុកទៅក្រៅប្រទេស ប្រចាំខែនីមួយៗ បានពិនិត្យឃើញថានៅតែបន្តមានជាប្រក្រតី ជាក់ស្តែងដូចមានតារាងស្ថិតិខាងក្រោមៈ

| ល.រ | បរិយាយ | ចំនួនមនុស្ស | ចំនួនស្ត្រី |
|---|---|---|---|
| ១ | ខែមេសា | ៧៦.៣១៩ នាក់ | ៣២.៩៤២ នាក់ |
| ២ | ខែឧសភា | ៨១.៧៧០ នាក់ | ៣៥.២៤៩ នាក់ |
| ៣ | ខែមិថុនា | ៨៧.៣៩២ នាក់ | ៣៧.៦៦០ នាក់ |

- ស្នងការដ្ឋាននគរបាលខេត្តបាត់ដំបងៈ កម្លាំងល្បាតតាមខ្សែបន្ទាត់ព្រំដែន របស់វរៈសេនាតូចការពារព្រំដែនគោកលេខ ៨១៧ ៨១៩ ៨២៣ និង ៣១០ បានចេញល្បាតតាមបន្ទាត់ព្រំដែន ដើម្បីទប់ស្កាត់ការលួចឆ្លងដែនខុសច្បាប់ ចំនួន ១៦៥លើក ហើយបានប្រទះឃើញពលករឆ្លង

ដែនខុសច្បាប់ទេ ចំនួន ៦៨៤នាក់ (ស្រី ២៨៨នាក់ អនីតិជន ៤១នាក់) បានធ្វើការអប់រំ និងឲ្យត្រឡប់ទៅផ្ទះវិញ។

- ស្នងការដ្ឋាននគរបាលខេត្តរតនគិរី៖ កម្លាំងល្បាតតាមខ្សែបន្ទាត់ព្រំដែន របស់វរនគរបាលការពារព្រំដែនគោក បានចេញល្បាតតាមបន្ទាត់ព្រំដែនភូមិសាស្ត្ររបស់ខ្លួន ចំនួន ៩៨លើក (ព្រំដែនកម្ពុជាវៀតណាម ៧៤លើក និងព្រំដែនកម្ពុជា-ឡាវ ២៤លើក)។

**ខ.២.២. វិធានការបង្ការ ទប់ស្កាត់ តាមជំនាញគ្រប់គ្រងគោលដៅសង្ស័យបម្រើសេវាកម្មផ្លូវភេទ**

- អគ្គស្នងការដ្ឋាននគរបាលជាតិ
- ស្នងការដ្ឋាននគរបាលខេត្ត ស្វាយរៀង ក្រចេះ និងខេត្តមណ្ឌលគិរី បានធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ចារកម្ម និងផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់ម្ចាស់អាជីវកម្ម ភោជនីដ្ឋាន ផ្ទះសំណាក់សណ្ឋាគារ ម៉ាស្សា ចំនួន ២៦៦គោលដៅ មនុស្សចំនួន ២៤.៩៥១នាក់ (ស្រី ១២.៧១៥នាក់)។
- ស្នងការដ្ឋាននគរបាលខេត្ត សៀមរាប ស្វាយរៀង តាកែវ រតនគិរី ក្រចេះ កំពង់ស្ពឺ ព្រៃវែង និងខេត្តព្រះវិហារ ល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទ ចំនួន ១០៧លើក។

**ខ.២.៣. ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស**

- ក្រសួងមហាផ្ទៃ

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) នៃច្រកចេញចូលតែមួយ របស់ក្រសួងមហាផ្ទៃទទួលបន្ទុកការងារអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស បានធ្វើការសម្ភាសពលរដ្ឋខ្មែរ និងជនបរទេស សរុបចំនួន ១៦៧គូ ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ និងបានសាកសួរសុខទុក្ខនារីខ្មែរ ដែលរៀបការរួចហើយទៅរស់នៅប្រទេសកូរ៉េ និងប្រទេសចិន ដោយបានទំនាក់ទំនងតាមទូរស័ព្ទផ្ទាល់របស់សាម៉ីខ្លួនបានចំនួន ១៥នាក់ (រស់នៅជាមួយគ្រួសារសុខសប្បាយជាធម្មតា)។

## ខ.៣. កិច្ចការពារកុមារ ពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ

- ខេត្តប៉ៃលិន៖ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចុះធ្វើអធិការកិច្ច ដើម្បីទប់ស្កាត់ និងលុបបំបាត់នូវទម្រង់ជួញដូរធ្ងន់ធ្ងរលើពលកម្មកុមារ នៅតាមសហគ្រាស គ្រឹះស្ថាន ដែលមានប្រើប្រាស់កម្លាំងពលកម្មដូចជា សេឡូ កាស៊ីណូ ឡូតដ្ឋ ភោជនីយដ្ឋាន ចំនួន ៨០កន្លែង។
- ខេត្តក្រចេះ៖
  - មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត បានចុះត្រួតពិនិត្យមណ្ឌល អង្គការដំណឹងល្អចំនួន ០២។
  - ស្ថិតិកុមាររស់នៅក្នុងភូមិកុមារកម្ពុជា SOS មានចំនួន ៨៩នាក់ (ស្រី ៣៩នាក់)។
- ខេត្តតាកែវ ៖ មានមណ្ឌលថែរក្សាកុមារកំព្រា និងសហគមន៍ NGOs មានកុមារសរុប ២៥៦នាក់ (ស្រី ១២១នាក់)។
- ខេត្តកំពង់ឆ្នាំង៖ ស្នងការដ្ឋាននគរបាលខេត្តបានចុះត្រួតពិនិត្យសិប្បកម្មឡូតដ្ឋ ចំនួន ០៣កន្លែង ដោយពិនិត្យមិនឃើញមានកម្មករជាអនីតិជនទេ។
- ខេត្តពោធិ៍សាត់៖ មានមណ្ឌលថែរក្សាកុមារកំព្រា ចំនួន ១៣ (មណ្ឌលរដ្ឋ ០១ និងមណ្ឌលអង្គការ ១២) មានកុមារសរុប ១៩៦នាក់ (ស្រី ៩៣នាក់)។

- ខេត្តព្រះវិហារ៖ មានមណ្ឌលថែរក្សាកុមារកំព្រា ចំនួន ០៧ (មណ្ឌលរដ្ឋ ០១ និងមណ្ឌលអង្គការ-វិហារសាសនា ០៦) មានកុមារសរុប ២០៩នាក់ (ស្រី ៩១នាក់)។
- **ខេត្តមណ្ឌលគិរី៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះអធិការកិច្ចតាមបណ្តារោងចក្រ សហគ្រាស និងក្រុមហ៊ុន ចំនួន ០៧លើក។
- **ខេត្តព្រះសីហនុ៖** បន្តសហការជាមួយអង្គការម្លប់តាប៉ាង ធ្វើការទំនាក់ទំនងជាប្រចាំជាមួយបណ្តាញដែលបានដាក់ចំនួន **១.២២៧**នាក់ (ម៉ូតូឌុប ក្រុមម៉ូតូកង់បី ផ្ទះសំណាក់ សណ្ឋាគារ អ្នកលក់តាមឆ្នេរសមុទ្រ ភ្នាក់ងារទេសចរណ៍ និងសហគមន៍) ។
- ខេត្តបន្ទាយមានជ័យ៖ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះអធិការកិច្ចការងារសាមញ្ញ ចំនួន ០៤លើក (០៤ក្រុមហ៊ុន)។
- ខេត្តកែប៖ មានមណ្ឌលថែរក្សាកុមារកំព្រា ចំនួន ០១កន្លែង កុមារសរុប ៤៧នាក់ (ស្រី **១៧**នាក់)។

**ខ.៤. ការកាត់បន្ថយភាពងាយរងគ្រោះ តាមរយៈការផ្តល់ប័ណ្ណព្រំដែនដល់មុខសញ្ញាងាយរងគ្រោះ**

រដ្ឋបាលខេត្តចំនួន០៣ គឺខេត្តបន្ទាយមានជ័យ បាត់ដំបង និងខេត្តប៉ៃលិន ដែលមានច្រកប៉ុស្តិ៍អន្តរជាតិនៅតាមព្រំដែន បានផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ (Border Pass) សរុបចំនួន **១.១៥២**ប័ណ្ណ ដល់ពលរដ្ឋខ្មែរដែលរស់នៅក្នុងខេត្តជាប់ព្រំដែន មាន៖

- ខេត្តបាត់ដំបង ចំនួន ៥៦៣ប័ណ្ណ
- ខេត្តបន្ទាយមានជ័យ ចំនួន ៤៥៣ប័ណ្ណ
- ខេត្តប៉ៃលិន ចំនួន ១៣៦ប័ណ្ណ។

## គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### គ.១. ការងារអនុវត្តច្បាប់

លទ្ធផលបង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខាងក្រោមនេះទទួលបានពីអង្គភាព៖ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត (រាជធានីភ្នំពេញ ខេត្តបន្ទាយមានជ័យ បាត់ដំបង កំពង់ចាម កំពង់ឆ្នាំង កណ្តាល ក្រចេះ កោះកុង មណ្ឌលគិរី ព្រះវិហារ ព្រៃវែង ពោធិ៍សាត់ រតនគិរី សៀមរាប ខេត្តព្រះសីហនុ ឧត្តរមានជ័យ និងខេត្តត្បូងឃ្មុំ)។

#### គ.១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

អគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តច្បាប់) កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទសរុបចំនួន ៤៩ករណី (ធៀបនឹងត្រីមាសទី១ ឆ្នាំ២០២០ មានចំនួន **២៧**ករណី កើនឡើង ២២ករណី) ស្មើនឹង **៩១,៦៦%**។

ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន ៦៥នាក់ (ស្រី **១០**នាក់ អនីតិជន ០២នាក់) និងជនបរទេស **១២**នាក់ មានសញ្ជាតិ (ចិន ០៩នាក់ អាមេរិក ០១នាក់ អង់គ្លេស ០១នាក់ និងអ៊ីស្រាអែល ០១នាក់)។

សង្គ្រោះជនរងគ្រោះ ចំនួន **១៦៧**នាក់ មាន៖ អាយុក្រោម១៥ឆ្នាំ ៤៤នាក់ អាយុ១៥-១៧ឆ្នាំ **១០**នាក់ និងអាយុពី១៨ឆ្នាំឡើង ១១៣នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ច ២៥នាក់ និងប្រគល់ឲ្យគ្រួសារ **១៤២**នាក់) ក្នុងនោះមានចែកជា៖

***តារាងបូកសរុបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ***

| ល.រ | បរិយាយ | ករណី | ជនរងគ្រោះ | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|---|---|
| ១ | ខែមេសា | ០៩ ករណី | ០៩ នាក់ | ០៩ នាក់ | |
| ២ | ខែឧសភា | ១៥ ករណី | ២៥ នាក់ | ១៨ នាក់ | អាមេរិក១ |
| ៣ | ខែមិថុនា | ២៥ ករណី | ១៣៣ នាក់ | ៣៨ នាក់ | ចិន៩ អង់គ្លេស១ អ៊ីស្រាអែល១ |
| សរុបត្រីមាសទី២ | | ៤៩ ករណី | ១៦៧ នាក់ | ៦៥ នាក់ | ១២ នាក់ |

**ចែកចេញជា៖**

**១. ករណីអំពើជួញដូរមនុស្ស**

បង្ក្រាបបាន **២១**ករណី លើ**០៧**ករណី (កើន **១៤**ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន **២៦**នាក់ (ស្រី **០៧**នាក់) និងជនសង្ស័យជាជនបរទេស **០២**នាក់ (សញ្ជាតិអាមេរិក និងអ៊ីស្រាអែល)។

សង្គ្រោះជនរងគ្រោះ ចំនួន **១២៩**នាក់ មាន: អាយុក្រោម១៥ឆ្នាំ **១៤**នាក់ អាយុក្រោម១៥-១៧ឆ្នាំ **០៨**នាក់ និងអាយុពី១៨ឆ្នាំឡើង **១០៧**នាក់(ប្រគល់ឲ្យមន្ទីរសង្គមកិច្ច **២១**នាក់ និងប្រគល់ឲ្យគ្រួសារ **១០៨**នាក់)។

***តារាងស្ថិតិបទល្មើសអំពើជួញដូរមនុស្ស***

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|---|
| -ការនាំអនីតិជនជាអាទិ៍ចេញដោយមិនស្របច្បាប់ | ០១ | ០១ | ០១ | |
| -ការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅ | ០៣ | ០៣ | ០៣ | |
| -ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ១៣ | ១១៧ | ១៨ | |
| -ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ច | ០១ | ០១ | ០១ | |
| -អំពើលក់ដូរមនុស្សដោយមានគោលដៅ | ០១ | ០១ | ០១ | |
| -ការទិញពេស្យាចារកុមារ | ០២ | ០៦ | ០២ | អាមេរិក ១<br>អ៊ីស្រាអែល ១ |
| *សរុប* | *២១ ករណី* | *១២៩ នាក់* | *២៦ នាក់* | *០២ នាក់* |

**២. ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ**

បង្ក្រាបបាន ២៨ករណី លើ២០ករណី (កើនឡើង ០៨ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ៣៩នាក់ (ស្រី **០២**នាក់ អនីតិជន **០២**នាក់) និងជនសង្ស័យជាជនបរទេស ចំនួន **១០**នាក់ សញ្ជាតិចិន **០៩**នាក់ អង់គ្លេស **០១**នាក់។

សង្គ្រោះជនរងគ្រោះចំនួន ៣៨នាក់ មាន: អាយុក្រោម១៥ឆ្នាំ ២៩នាក់ អាយុ១៥ឆ្នាំ១៧ឆ្នាំ ០២នាក់ និងអាយុពីឆ្នាំឡើង ០៧នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ច ០៤នាក់ និងប្រគល់ឲ្យគ្រួសារ ៣៤នាក់)។

***តារាងស្ថិតិបទល្មើសអំពើធ្វើអាជីវកម្មផ្លូវភេទ***

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|---|
| -ការចាប់ពង្រត់ ការឃុំឃាំង ឬការបង្ខាំង | ០១ | ០១ | ០៩ | ចិន ៩ |
| -ការផ្តល់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ | ០១ | ០៤ | ០១ | |
| -រូបភាព និងសម្ភារ:អាសអាភាស | ០២ | ០៤ | ០៤ | |
| -រូបភាព និងសម្ភារ:អាសអាភាសនៃកុមារ | ០១ | ០៣ | ០១ | |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ១៨ | ២០ | ១៩ | អង់គ្លេស ១ |
| -អំពើអាសប្រចាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៥ | ០៦ | ០៥ (អនី.២) | |
| *សរុប* | *២៨ ករណី* | *៣៨ នាក់* | *៣៩ នាក់* | *១០ នាក់* |

## គ.២. កិច្ចការយុត្តិធម៌

ទិន្នន័យទទួលបានពីក្រុមការងារកិច្ចការយុត្តិធម៌ ដឹកនាំដោយក្រសួងយុត្តិធម៌ ដែលបានដកស្រង់ពីសាលាដំបូងរាជធានី-ខេត្ត បានធ្វើចំណាត់ការលើសំណុំរឿងបទល្មើសក្រោមច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ មាត្រាពាក់ព័ន្ធនៃក្រមព្រហ្មទណ្ឌ ជាលទ្ធផលតាមដំណាក់កាលនៃនីតិវិធីតុលាការ មានដូចខាងក្រោម៖

### គ.២.១. ចំណាត់ការរបស់អយ្យការអមសាលាដំបូងរាជធានី-ខេត្ត

ចំណាត់ការរបស់អយ្យការអមសាលាដំបូងរាជធានី-ខេត្ត សរុបមានចំនួន ៦៣ករណី ជនរងគ្រោះចំនួន ៨៣នាក់ (ស្រី ៧១នាក់) អនីតិជន ៤៦នាក់ (ស្រី ៤៥នាក់) ជនត្រូវចោទមានចំនួន ៧២នាក់ (ស្រី ២៧នាក់) ហើយបានចំណាត់ការដោយបានបញ្ជូនទៅស៊ើបសួរចំនួន ២៨ករណី តម្កល់ទុកឥតចាត់ការគ្មាន និងកំពុងចាត់ការចំនួន ៣៥ករណី ដូចមានតារាងលម្អិតខាងក្រោម៖

*តារាងចំណាត់ការរឿងក្តីជួញដូរមនុស្សរបស់អយ្យការអមសាលាដំបូងរាជធានី-ខេត្ត៖*

| ចំនួនករណី | ចំនួនជនរងគ្រោះ | | | | ចំនួនជនល្មើស | | | | ប្រភេទចំណាត់ការ | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | បញ្ជូនទៅស៊ើបសួរ | តម្កល់ទុកឥតចាត់ការ | កំពុងចាត់ការ |
| | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | | | |
| សរុប | ៧ | ៣០ | ៥ | ៤១ | ៤៣ | ២៧ | ២ | ០ | ២៨ | ០ | ៣៥ |
| ៦៣ | ៣៧ នាក់ | | ៤៦ នាក់ | | ៧០ នាក់ | | ០២ នាក់ | | ៦៣ ករណី | | |

### គ.២.២. ចំណាត់ការរបស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានី-ខេត្ត

ចំណាត់ការរបស់ចៅក្រមស៊ើបសួររាជធានី-ខេត្ត សរុបមានចំនួន ៥៨ករណី ជនរងគ្រោះចំនួន ៧៩នាក់ (ស្រី ៧០នាក់) អនីតិជន ៤៣នាក់(ស្រី ៣៨នាក់) ជនត្រូវចោទមានចំនួន ៦៣នាក់ (ស្រី ០៣នាក់) នៅក្នុងឃុំចំនួន ៥៩នាក់(ស្រី ០៣នាក់) នៅក្រៅឃុំចំនួន ០៥នាក់ និងបានចំណាត់ការបញ្ជូនទៅជម្រះចំនួន ៣៥ករណី លើកលែងចោទគ្មាន និងកំពុងចាត់ការចំនួន ២៣ករណី ដូចមានតារាងលម្អិតខាងក្រោម៖

*តារាងចំណាត់ការរឿងក្តីជួញដូរមនុស្សរបស់ចៅក្រមស៊ើបសួររាជធានី-ខេត្ត៖*

| ចំនួនករណី | ចំនួនជនរងគ្រោះ | | | | ចំនួនជនត្រូវចោទ | | | | នៅក្នុងឃុំ | | | | នៅក្រៅឃុំ | | | | ប្រភេទចំណាត់ការ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | ជូនទៅជម្រះ | លើកលែងចោទ | កំពុងចាត់ការ |
| | ប | ស | ប | ស | ប | ស | ប | ស | ប | ស | ប | ស | ប | ស | ប | ស | | | |
| សរុប | ៤ | ៣២ | ៥ | ៣៨ | ៥១ | ៣ | ១០ | ០ | ៥១ | ៣ | ៥ | ០ | ០ | ០ | ៥ | ០ | ៣៥ | ០ | ២៣ |
| ៥៨ | ៣៦ នាក់ | | ៤៣ នាក់ | | ៥៤ នាក់ | | ១០ នាក់ | | ៥៩ នាក់ | | | | ០៥ នាក់ | | | | ៥៨ ករណី | | |

### គ.២.៣. ចំណាត់ការរបស់ចៅក្រមជំនុំជម្រះ នៃសាលាដំបូងរាជធានី-ខេត្ត

ចំណាត់ការរបស់ចៅក្រមជំនុំជម្រះរាជធានី-ខេត្ត សរុបមានចំនួន ៤៨ករណី ជនរងគ្រោះចំនួន ៧៦នាក់ (ស្រី ៧០នាក់) អនីតិជន ៥២នាក់(ស្រី ៤៧នាក់) ជនជាប់ចោទសរុប ៥៣នាក់(ស្រី ១៨នាក់) និងប្រភេទចំណាត់ការ(ទោសព្យួរគ្មាន ពិន័យជាប្រាក់គ្មាន រួចផុតពីបទចោទគ្មាន រំលត់បណ្តឹងអាជ្ញាគ្មាន ចាត់ការរួច ៣២ករណី ផ្តន្ទាទោសដាក់ពន្ធនាគារក្នុងឃុំ ៤៩នាក់ នៅក្រៅឃុំគ្មាន និងកំពង់ចាត់ការ ១៦ករណី) ដូចមានតារាងលម្អិតខាងក្រោម៖

*តារាងចំណាត់ការរឿងក្តីជួញដូរមនុស្សរបស់ចៅក្រមជំនុំជម្រះរាជធានី-ខេត្ត៖*

| ចំនួនករណី | ចំនួនជនរងគ្រោះ | | ចំនួនជនជាប់ចោទ | ប្រភេទចំណាត់ការ | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | អនីតិជន | | ទោសព្យួរ | ពិន័យជាប្រាក់ | រួចផុតពីបទចោទ | រំលត់បណ្តឹងអាជ្ញា | ចាត់ការរួច | ផ្តន្ទាទោសពន្ធនាគារ | កំពុងចាត់ការ |

<table>
<tr><td rowspan="3">សរុប ៤៨</td><td>ប</td><td>ស</td><td>ប</td><td>ស</td><td>ប</td><td>ស</td><td rowspan="3">០</td><td rowspan="3">០</td><td rowspan="3">០</td><td rowspan="3">០</td><td rowspan="3">៣២ ករណី</td><td>ក្នុងឃុំ</td><td>ក្រៅឃុំ</td><td></td></tr>
<tr><td>១</td><td>២៣</td><td>៥</td><td>៤៧</td><td>៣៥</td><td>១៨</td><td rowspan="2">៤៩ នាក់</td><td rowspan="2">០</td><td rowspan="2">១៦ ករណី</td></tr>
<tr><td colspan="2">២៤ នាក់</td><td colspan="2">៥២ នាក់</td><td colspan="2">៥៣ នាក់</td></tr>
</table>

## ឃ. កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

### ឃ.១. ការទទួល និងសម្ភាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និង ផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ

#### ឃ.១.១. ការទទួល និងសម្ភាសពលករបញ្ជូនត្រឡប់

- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

បានជួយអន្តរាគមន៍ពលរដ្ឋខ្មែររងគ្រោះឲ្យត្រឡប់មកកម្ពុជាវិញ ចំនួន ១.១៣៣នាក់ ក្នុងនោះមាន ប្រទេសថៃ ១.១០៤នាក់ វៀតណាម ១៩នាក់ និងប្រទេសចិន ១០នាក់។

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

ក្រុមការងារការពារជនរងគ្រោះ សហការជាអង្គការនានា បានទទួលជនរងគ្រោះ និងងាយរងគ្រោះ ដោយអំពើជួញដូរមនុស្ស ៖

• បានធ្វើមាតុភូមិនិវត្តន៍ពីប្រទេសនានា ចំនួន ១១នាក់(ស្ត្រី ១០នាក់) ក្នុងនោះមកពីប្រទេសចិន ១០នាក់(តាមប្រលានយន្តហោះអន្តរជាតិភ្នំពេញ និងច្រព្រំដែនបាវិត) ថៃ ០១នាក់ (តាមច្រកអន្តរជាតិ ប៉ោយប៉ែត) ក្នុងនោះករណី(*អាពាហ៍ពិពាហ៍ផ្ទុយ ពីឆន្ទៈបង្ខំ១០នាក់ ជួញដូរផ្លូវភេទ ០៣នាក់និងជួញដូរមនុស្ស ០១នាក់*)។

• មណ្ឌលសំចតប៉ោយប៉ែត បានទទួលជនងាយរងគ្រោះនិរទេសពីប្រទេសថៃ សរុបចំនួន៨,៧២១នាក់ (ស្ត្រី៣,៥២៩នាក់ កុមារា៣៧៧នាក់ កុមារី១៩៤នាក់) និងបានធ្វើការសម្ភាសន៍ដើម្បីកំណត់ អត្តសញ្ញាណរកមុខសញ្ញា ជនរងគ្រោះ និងងាយរងគ្រោះចំនួនសរុប០៣នាក់ (ស្ត្រី០១នាក់ កុមារា០១នាក់ កុមារី១០នាក់ ) ហើយផ្តល់ការស្នាក់នៅរយៈពេលខ្លីចំនួន០៣នាក់ បានបញ្ជូនទៅ អង្គការតំណក់ទឹក០១នាក់ អង្គការសាម៉ារីតាន់ភីស០១នាក់ និងអង្គការអន្តរជាតិទេសន្តរប្រវេស៍(MOI) ០១នាក់ ដើម្បីទទួលបានសេវាស្នាក់នៅបណ្តោះអាសន្ន ហូបចុក និងផ្តល់សោហ៊ុយ ធ្វើដំណើរត្រឡប់ទៅផ្ទះវិញ។

- អគ្គស្នងការដ្ឋាននគរបាលជាតិ

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានទទួល និងសម្ភាសពលករខ្មែររងគ្រោះ ដែលត្រឡប់ពីប្រទេសចិន ចំនួន ០៥នាក់(ស្រី) តាមការសម្ភាសបានឲ្យដឹងថា ពលរដ្ឋទាំងនោះទៅតាមរយៈមេខ្យល់។

- អគ្គនាយកដ្ឋានអន្តោប្រវេសន៍

ពលរដ្ឋខ្មែរត្រូវអាជ្ញាធរបរទេសបញ្ជូនត្រឡប់មកវិញ (ស្នាក់នៅ និងធ្វើការខុសច្បាប់) ទាំងផ្លូវគោក និងផ្លូវអាកាសសរុបចំនួន ៣៩លើក មនុស្សចំនួន ៣៦២នាក់ (ស្រី ១០៤នាក់) កុមារ ២៣នាក់ លើ ៤១លើក មនុស្សចំនួន ៤១៦នាក់ (ស្រី ១៤៦នាក់) កុមារ ៣១នាក់ ថយចុះចំនួន ១៨នាក់ ស្មើនឹង ៩៩,៩៧% ក្នុង នោះរួមមាន៖

- ច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ ចំនួន ៣៦លើក មនុស្សចំនួន ៣៥៥នាក់ (ស្រី ១០១នាក់) កុមារ ២៣នាក់។
- ច្រកទ្វារអាកាសយន្តដ្ឋានអន្តរជាតិភ្នំពេញ ចំនួន ០៣លើក មនុស្សចំនួន ០៧នាក់ (០៣នាក់) (ប្រទេសចិន ០៧នាក់)។

- ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត

ស្នងការដ្ឋាននគរបាលខេត្ត ចំនួន០២ បានទទួល និងសម្ភាសពលករខ្មែរ ដែលអាជ្ញាធរបរទេសចាប់បញ្ជូនត្រឡប់មកកម្ពុជាវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ និងវៀតណាម ចំនួន ៥០លើក មនុស្សចំនួន ៥១៨នាក់( ស្រី ២៥៥នាក់ អនីតិជន ៦៧នាក់) ក្នុងនោះមាន៖

- ខេត្តប៉ៃលិន ចំនួន ១៨លើក មនុស្សចំនួន ៣៧២នាក់ (ស្រី ១៧៣នាក់) អនីតិជនចំនួន ២៨នាក់។
- ខេត្តកោះកុង ចំនួន ២៥លើក មនុស្សចំនួន ៨៨នាក់ (ស្រី ៤២នាក់) អនីតិជនចំនួន ១៨នាក់។
- ខេត្តស្វាយរៀង ចំនួន ០៦លើក មនុស្សចំនួន ៣០នាក់ (ស្រី ២៧នាក់) អនីតិជន ១៣នាក់។

ខេត្តបន្ទាយមានជ័យ ចំនួន ០១លើក មនុស្សចំនួន ២៨នាក់ (ស្រី ១៣នាក់) អនីតិជនចំនួន ០៨នាក់។

**ឃ.២. ការស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស**

-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា( ស.អ.យ)

ក្រុមការងារការពារជនរងគ្រោះ និងមន្ទីរសង្គមកិច្ច រាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានបញ្ជូនជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលបានសេវាស្នាក់នៅ និងការស្តារនីតិសម្បទារបស់អង្គការមូនិធិហាការអន្តរជាតិ សរុបចំនួន ៧៦នាក់(ស្ត្រី ០៩នាក់ កុមារា ១៦នាក់ កុមារី ៥១នាក់)ក្នុងនោះ ជាករណី: *( ធ្វអាជីវកម្មផ្លូវភេទ ០៥នាក់ រំលោភបំពានផ្លូវភេទ ៦៤នាក់ កេងប្រវ័ញ្ចកម្លាំងពលកម្ម ០៧នាក់ )*។

**ឃ.៣. ការធ្វើសមាហរណកម្មជនរងគ្រោះ និងជនងាយរងគ្រោះ**

-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា( ស.អ.យ)

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានសហការជាមួយអាជ្ញាធរ មូលដ្ឋាន និងអង្គការដៃគូ បានធ្វើសមាហរណកម្មជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ត្រឡប់ទៅសហគមន៍វិញចំនួន ០៨នាក់ (ស្ត្រី ០៥នាក់) ក្នុងនោះមានករណី *(អាពាហ៍ពិពាហ៍ដោយផ្ទុយពីឆន្ទៈបង្ខំ០៥នាក់ និងជួញដូរកម្លាំងពលកម្ម ០៣នាក់ )* ដោយមានកិច្ចសហការពីអង្គការដៃគូ។

## III. ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល

### ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

#### ក.១. ការងារបណ្តុះបណ្តាល

ក.១.១.ការបណ្តុះបណ្តាលក្នុងប្រទេស

<u>តារាងវគ្គបណ្តុះបណ្តាល</u>

| ល.រ | សកម្មភាព | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមជានារី |
|---|---|---|---|---|
| ១ | -ខេត្តស្វាយរៀង៖ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សហការជាមួយក្រុមហ៊ុនសហគ្រាស ចំនួន ២០ បើកវគ្គបណ្តុះបណ្តាល ស្តីពីបំនិនជីវិត និងច្បាប់ស្តីពីការងារ។ | ០១ | ៤២៦ | ២៨៧ |
| | -ខេត្តកំពត៖ លេខាធិការដ្ឋាន គ.ខ.ប.ជ សហការជាមួយអង្គការជំនួយផ្លូវច្បាប់ដល់ស្ត្រី និងកុមារ បើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាព ដល់សមាជិកលេខាធិការដ្ឋាន ស្តីពីសិទ្ធិរបស់ពលករចំណាកស្រុកធ្វើការលើទូកនេសាទប្រទេសថៃ។ | ០១ | ២០ | ០៧ |

| | | | | |
|---|---|---|---|---|
| | -ខេត្តកោះកុង៖ លេខាធិការដ្ឋាន គ.ខ.ប.ជ សហការជាមួយអង្គការជំនួយផ្លូវច្បាប់ដល់ស្ត្រី និងកុមារ បើកវគ្គបណ្តុះបណ្តាលសម្រាប់គ្រូបង្គោល ស្តីពីសិទ្ធិរបស់ពលករចំណាកស្រុកធ្វើការលើទូកនេសាទប្រទេសថៃ។ | ០១ | ២៤ | ១០ |
| | សរុប | ០៣ វគ្គ | ៤៧០ នាក់ | ២០៤ នាក់ |

## ខ. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

### ខ.១. កិច្ចប្រជុំ ជាអន្តរជាតិនៅក្នុងប្រទេស និងក្រៅប្រទេស

➢ កិច្ចប្រជុំក្នុងប្រទេស

▪ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)

- សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញចូលរួមជាអធិបតីភាពដ៏ខ្ពង់ខ្ពស់៖
  - ○ ក្នុងពិធីបើកកិច្ចប្រជុំផ្សព្វផ្សាយ របាយការណ៍ជាតិ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៩ និងលើកទិសដៅអនុវត្ត ឆ្នាំ២០២០ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានសភាពចូលរួមមកពីបណ្តាក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ និង២៥រាជធានី-ខេត្ត និងអង្គការក្រៅរដ្ឋាភិបាល សរុបប្រមាណ ២០០នាក់ នៅទីស្តីការក្រសួងមហាផ្ទៃ។
  - ○ ក្នុងកិច្ចប្រជុំពិគ្រោះយោបល់ ដើម្បីពិនិត្យលទ្ធភាពក្នុងការឆ្លើយតបទៅនឹងតម្រូវការរយៈពេលខ្លី មធ្យម និងវែង របស់ពលករចំណាកស្រុកក្នុងស្ថានភាពនៃជំងឺកូវីដ-១៩ នៅទីស្តីការក្រសួងមហាផ្ទៃ។
- លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញចូលរួមដឹកនាំកិច្ចប្រជុំ៖
  - ○ ស្តីពីកិច្ចសហការក្នុងការឆ្លើយតបនឹងវិបត្តិកូវីដ-១៩ ក្នុងចំណោមពលករ ចំណាកស្រុក និងសហគមន៍ នៅទីស្តីការក្រសួងមហាផ្ទៃ អ្នកចូលរួមចំនួន **៧២**នាក់ (ស្រី **២៦**នាក់)។
  - ○ ស្តីពីការពិនិត្យផែនការសកម្មភាព ឆ្នាំ២០២០ ចំនួន ០២លើក ដើម្បីដាក់ជូនក្រសួងមហាផ្ទៃរៀបចំកម្មវិធីឆ្លងកិច្ចប្រជុំនេះ អ្នកចូលរួមចំនួន **១៣**នាក់ (ស្រី ០៤នាក់) នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
  - ○ ស្តីពីការរួបរួមគ្នាប្រឆាំងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ តាមប្រព័ន្ធអ៊ីនធឺណែត រៀបចំឡើងដោយ IJM Phillipines។
  - ○ ពិនិត្យ និងផ្តល់យោបល់ទៅលើខ្លឹមសារ សេចក្តីព្រាងសៀវភៅអប់រំ និងលំនាំ នៃការបង្រៀន ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស សម្រាប់ថ្នាក់បឋមសិក្សា ទាំងរដ្ឋ និងឯកជន អ្នកចូលរួមចំនួន **១៥**នាក់ (ស្រី ០៣នាក់) នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
  - ○ ស្តីពីការពង្រឹងវិធានការទប់ស្កាត់ និងគ្រប់គ្រងការឆ្លងដែនដោយខុសច្បាប់ របស់ពលករកម្ពុជា។
  - ○ ស្តីពីសេចក្តីព្រាងខ្លឹមសារអនុស្សរណៈនៃការយោគយល់គ្នា រវាងអង្គការមូលនីធិA21 ជាមួយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
  - ○ ស្តីពីផែនការសកម្មភាពនៃកិច្ចសហការ ក្នុងការបង្ការជំងឺកូវីដ-១៩ ទៅដល់ ពលករចំណាកស្រុកដែលងាយរងគ្រោះ និងក្នុងសហគមន៍ រវាងអង្គការដែលនៅក្រោមអង្គការសហប្រជាជាតិ មាន

អង្គការយូនីសេហ្វ (WHO) (IOM) (UNFPA) ជាមួយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។

- ពិភាក្សា អំពីគម្រោងកម្មវិធីការការពារពលករទេសន្តប្រវេសន៍ ដែលមាតុភូមិនិវត្តន៍ និងសហគមន៍ ពីហានិភ័យឆ្លងជំងឺកូវីដ-១៩ ទ្រង់ទ្រាយធំ និងការផ្តល់សេវាចាំបាច់នានា ក្នុងមូលដ្ឋាន នៅទីស្តីការក្រសួងមហាផ្ទៃ។
- ស្តីពីសេចក្តីប្រកាសរបស់ប្រទេសកាណាដា ទទួលសំណើគម្រោងអាស៊ាន ក្រោមមូលនិធិអាស៊ាន-កាណាដា សម្រាប់ផ្តួចផ្តើមថ្នាក់មូលដ្ឋាន ឆ្នាំ២០២០-២០២១ ស្តីពីការរៀបចំឯកសារលើគម្រោងក្នុងមូលនិធិពិសេស នៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង (NSC-MLC) សម្រាប់ឆ្នាំ២០២១ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
- ពិភាក្សាលើសេចក្តីសម្រេច ស្តីពីការបង្កើត "មណ្ឌលទទួលពលករចំណាកស្រុក ច្រកដូង" អ្នកចូលរួមចំនួន ១៨នាក់ (ស្រី ០៤នាក់) នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
- ស្តីពីការអនុវត្តគោលនយោបាយប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អ្នកចូលរួមចំនួន ០៦នាក់ (ស្រី ០៣នាក់) នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
- ពិភាក្សាពិគ្រោះយោបល់ ស្តីពីការចាត់ចែងការងារ រវាងស្ថាប័ន និងដៃគូពាក់ព័ន្ធសម្រាប់ការងារ អនុវត្តក្នុងមណ្ឌលទទួលពលករចំណាកស្រុកកំរៀង ខេត្តបាត់ដំបង អ្នកចូលរួមចំនួន ០៧នាក់ (ស្រី ០៤នាក់) នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
- ពិភាក្សាការងារជាមួយអង្គការជំនួយផ្លូវច្បាប់ដល់ស្ត្រី និងកុមារ និងវិទ្យាស្ថានបច្ចេកវិទ្យាអាស៊ី ជាស្ត្រី០២រូប ដែលសុំកិច្ចសហការធ្វើការសិក្សាស្រាវជ្រាវស្តីពី "**ប្រសិទ្ធិភាពនៃការអនុវត្តច្បាប់ គោលនយោបាយ និងកិច្ចព្រមព្រៀងទ្វេភាគី រវាងកម្ពុជា-ថៃ ក្នុងកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**"នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
- ស្តីពីការពង្រឹងវិធានការទប់ស្កាត់ និងគ្រប់គ្រងការឆ្លងដែនដោយខុសច្បាប់របស់ពលករកម្ពុជា ដែលមានការចូលរួមពីថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ អភិបាល នៃគណៈអភិបាល អភិបាលរង ខេត្តជាប់ព្រំដែនទាំង៤ (មានបន្ទាយមានជ័យ បាត់ដំបង សៀមរាប ឧត្តរមានជ័យ) អគ្គនាយករងរដ្ឋបាល លេខាធិការដ្ឋានគ.ខ.ប.ជ មេបញ្ជាការ និង តំណាងពីខាងវរព្រំដែននៃអគ្គស្នងការដ្ឋាននគរបាលជាតិ នាយកទីចាត់ការព្រំដែន អាជ្ញាធរ តំណាងពីមន្ទីរពាក់ព័ន្ធខេត្ត សមត្ថកិច្ចតាមបណ្តាច្រកគោលដៅនានា អង្គការ(IOM) នៅសាលាខេត្តបន្ទាយមានជ័យ។

## ១.២. ជំនួបពិភាក្សាការងារ

- លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានទទួលជួបសំណេះសំណាលការងារជាមួយប្រធាន និងក្រុមការងារ របស់អង្គការអែម(AIM) និងទទួលបាននូវការឧបត្ថម្ភនូវអង្ករ និងសម្ភារបរិក្ខាមួយចំនួន សម្រាប់ប្រើប្រាស់ និងផ្គត់ផ្គង់នៅមណ្ឌលសំចតទទួលពលករដែលត្រលប់មកពីក្រៅប្រទេស ជាពិសេសក្នុងយុទ្ធនាការទប់ស្កាត់ជំងឺកូវីដ-១៩ នេះ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។

## ១.៣. ការងារសម្របសម្រួល

ការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេសគឺ ៩៥លើក មានអ្នកចូលរួមសរុប ១.៩២៧នាក់ (ស្រី ៦៧១នាក់) ក្នុងនោះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ៣២លើក និងលេខាធិការដ្ឋានរាជធានី-ខេត្ត ចំនួន ៦៣លើក។ (**ឧបសម្ព័ន្ធ**)

## IV. **ការសន្និដ្ឋានវាយតម្លៃ**

### **ក.ចំណុចខ្លាំង**

តាមរយៈការខិតខំប្រឹងប្រែង របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឲ្យកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិផងដែរ។
- ការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានផ្តល់អនុសាសន៍ ០៤ចំណុច និងវិធានការ ០៦ចំណុច របស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន គ.ជ.ប.ជ** គឺជាប្រទីបដ៏ល្អដល់គ.ជ.ប.ជ និងគ្រប់សមាសភាពដែលជាយន្តការក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- យើងមានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។
- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួងស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

### **ខ. ចំណុចខ្វះខាត ឬភាពប្រឈម**

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម និងសេសសល់មួយចំនួនដូចជា៖

- ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួននៅមិនទាន់ចេះសហការគ្នាជាប្រព័ន្ធ និងបែងចែកការទទួលខុសត្រូវបន្តរហូតចប់ការងារ។
- ការធ្វើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងឲ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស។
- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណា ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ។

### **គ. សំណូមពរ**

- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការដៃគូត្រូវយកចិត្តទុកដាក់ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន។
- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព និងអ្នកពាក់ព័ន្ធ ផ្តល់របាយការណ៍ឲ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែ របស់ក្រុមការងារអន្តរជំនាញ តាមវិស័យនីមួយៗ ដើម្បីប្រសិទ្ធភាពការងារ។
- ស្នើឲ្យលេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ ផ្តល់របាយការណ៍ឲ្យបានទៀងទាត់ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។

- បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឲ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។
- ស្នើសុំក្រសួង ស្ថាប័ន អង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់អនុវត្តតាមសេចក្តីសម្រេច ស្តីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលប្រធាន គ.ជ.ប.ជ បានសម្រេច។

### ឃ. សន្និដ្ឋាន

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង ៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។
- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅ ការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឲ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារ និងការចងក្រងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។
- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយអ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាមិនខាន។

## V. ទិសដៅត្រីមាសទី៣ ឆ្នាំ ២០២០

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឲ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធនឹងការងារគ្រប់គ្រងគ្រប់ផ្នែក ដល់មន្ត្រីជំនាញក្នុងក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត ដើម្បីពង្រឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

២. បន្តធ្វើសេចក្តីសម្រេចកែសម្រួលសមាសភាពក្រុមការងារអន្តរក្រសួង ស្ថាប័ន និងគណៈកម្មាធិការរាជធានី ខេត្ត ។

៣. ពិនិត្យ តាមដាន ការអនុវត្ត កិច្ចព្រមព្រៀង និងអនុស្សារណៈ ទ្វេភាគី និងពហុភាគី ជាមួយដៃគូពាក់ព័ន្ធជាតិ និងអន្តរជាតិ ។

៤. រៀបចំប្រព័ន្ធប្រមូល ចងក្រង និងចែកចាយទិន្នន័យ តាមផ្នែកពាក់ព័ន្ធសំខាន់ៗ ។

៥. ពង្រឹងសកម្មភាពទទួលពលករ ការស្រាវជ្រាវទិន្នន័យ ដើម្បីផ្តល់សេវាជូនពលករដែលត្រូវបានបញ្ជូនត្រឡប់ពីអាជ្ញាធរបរទេស និងពលកររិលត្រឡប់វិញនៅតាមច្រកព្រំដែនសំខាន់ៗ ។

៦. សហការជាមួយអង្គការការីតាសស្វីស និងរដ្ឋបាល ខេត្តបាត់ដំបង សាងសង់ និងដាក់ឲ្យដំណើរការមណ្ឌលទទួលពលករ នៅស្រុកកំរៀង ។

៧. សិក្ខាសាលា ស្តីពី «យន្តការនៃការទទួលពលករ និងការគ្រប់គ្រង នៅមណ្ឌលទទួលពលករ កំរៀង»។

៨. ជំរុញការអនុវត្តកម្មវិធីរួមគ្នាជាមួយអង្គការសហប្រជាជាតិ ក្នុងខេត្តបាត់ដំបង បន្ទាយមានជ័យ និងសៀមរាប ។

៩. ពង្រឹងការងារដឹកនាំរបស់ប្រធានក្រុមការងារជំនាញអន្តរក្រសួងទាំង ០៦ ដើម្បីរួមគ្នាដោះស្រាយបញ្ហាប្រឈម (ក្រោមការដឹកនាំរបស់សម្តេចក្រឡាហោម ប្រធានគ.ជ.ប.ជ)។

១០. រៀបចំសិក្ខាសាលាថ្នាក់ជាតិ ស្តីពីកិច្ចការពារកុមារ ក្នុងទេសន្តរប្រវេសន៍ ពីអំពើជួញដូរមនុស្ស និងការរំលោភបំពាន ។

១១. រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ កម្រិតថ្នាក់ដឹកនាំ ដើម្បីសម្រេចជ្រើសរើសសូចនាករជាអាទិភាព សម្រាប់អនុវត្ត កតិកាសញ្ញាពិភពលោក ស្តីពី «ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់» ។

១២. បន្តចុះអនុស្សរណៈ ជាមួយអង្គការដៃគូពាក់ព័ន្ធ ។

១៣. ក្រុមការងារបង្ការទប់ស្កាត់ អន្តរក្រសួង រៀបចំបោះពុម្ពលើកទី១ និងផ្សព្វផ្សាយ សៀវភៅសិក្សាអប់រំនិងលំនាំវិធីនៃការបង្រៀន «ស្តីពី ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស» សម្រាប់ថ្នាក់បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ និងបើកវគ្គបណ្តុះបណ្តាលនៅសាលាគរុកោសល្យភូមិភាគទូទាំងប្រទេស ។

១៤. អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ រៀបចំសិក្ខាសាលាអន្តរស្ថាប័ន ដើម្បីពិភាក្សាអំពីយន្តការប្រមូលទិន្នន័យថ្នាក់ជាតិ ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ជាពិសេសទិន្នន័យនៃការអនុវត្តច្បាប់ ការផ្តន្ទាទោស និងការងារការពារជនរងគ្រោះ ឲ្យមានសង្គតិភាព ។

១៥. រៀបចំយន្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ការផ្តល់សេវា ដល់ជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស នៅតាមមណ្ឌល និងនៅតាមសហគមន៍ ។

១៦. បន្តរៀបចំវគ្គបណ្តុះបណ្តាល «ស្តីពី បែបបទ និងនីតិវិធី នៃការកំណត់អត្តសញ្ញាណបឋមជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប» ដល់លេខាធិការដ្ឋាន ខេត្ត បាត់ដំបង ឧត្តរមានជ័យ និងពោធិសាត់។

១៧. រៀបចំឧបករណ៍វាយតម្លៃអំពី ភាពប្រឈម និងមេរៀនទទួលបាន នៃ«ការអនុវត្តនីតិវិធីនៃការកំណត់អត្តសញ្ញាណបឋមជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប» ក្នុងខេត្ត ដែលបានបណ្តុះបណ្តាលរួចហើយ ។

១៨. បន្តស៊ើបអង្កេត ស្រាវជ្រាវ និងបង្ក្រាប បទល្មើសពាក់ព័ន្ធអំពើជួញដូរមនុស្ស ។

១៩. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសកិច្ចសហការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ ក្នុងវិស័យព្រហ្មទណ្ឌជាមួយប្រទេសពាក់ព័ន្ធ ។

២០. បន្តពិគ្រោះយោបល់ និងពិនិត្យឡើងវិញខ្លឹមសារសេចក្តីព្រាងច្បាប់ ស្តីពីអំពើពពោះជំនួស ។

២១. ត្រៀមខ្លឹមសារសម្រាប់ ឧទ្ទិសដល់ទិវាជាតិ១២ធ្នូ

២២. បន្តរៀបចំផែនការអនុវត្តគោលបំណងអាទិភាព GCM និងអនុសញ្ញាអាស៊ាន ។

២៣. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយប្រយុទ្ធប្រឆាំងជម្ងឺកូវីដ ១៩ និងគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ៕ Pheaktha

ថ្ងៃព្រ.ហ...១៣កើត ខែកត្តិក ឆ្នាំ ជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២០

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជូ_ប៊ុនអេង**

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

**"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"**

- ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន
- សមាជិកក្រុមការងារគ.ជ.ប.ជ
- អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

**"ដើម្បីជូនជ្រាប"**

- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី១

## តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន ៩៥លើក) មនុស្សចំនួន ១.៩២៧នាក់ (ស្រី ៦៧១នាក់)

| ស្ថាប័នសម្របសម្រួល | សកម្មភាព |
| --- | --- |
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) | ▪ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ៖<br>- បានដឹកនាំក្រុមការងារគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងសហការជាមួយអង្គការដៃគូអភិវឌ្ឍ ការីតាសស្វីស និងអង្គការ IOM ក្រុមការងារសាលាស្រុកកំរៀង មន្ត្រីបច្ចេកទេសផ្នែកសាងសង់ បានចុះពិនិត្យ និងសិក្សាពីស្ថានភាពដីសម្រាប់សាងសង់មណ្ឌលសំចតពលករ នៅច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង។<br>- បានដឹកនាំក្រុមការងារគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចុះសួរសុខទុក្ខនៅទីកន្លែងចត្តាឡីស័កស្រុកមាល័យ និងកន្លែងទទួលពលករនៅច្រកដូង និងបានជួបប្រជុំជាមួយគណៈបញ្ជាការឯកភាពស្រុកកំរៀង ពាក់ព័ន្ធពីផែនការនៃគម្រោងសាងសង់មណ្ឌលទទួលពលករប្រចាំច្រកដូង ក្នុងស្រុកកំរៀង ខេត្តបាត់ដំបង។<br>- បានដឹកនាំក្រុមការងារគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងសហការជាមួយអង្គការអង្គការ AIM អង្គការ A21 និងអង្គការ ការីតាសកម្ពុជា ចុះសួរសុខទុក្ខ និងណែនាំពីវិធានការការពារបង្ការជំងឺកូវីដ-១៩ និងឧបត្ថម្ភជាសម្ភារៈមួយចំនួន ព្រមទាំងចែកខិត្តប័ណ្ណផ្សព្វផ្សាយ ដល់ក្រុមការងារមានមន្ត្រីមណ្ឌលសំចតប៉ោយប៉ែត មន្ត្រីសុខាភិបាល កងកម្លាំងរក្សាព្រំដែន ឃោធភូមិភាគរបស់ក្រសួងការពារជាតិ ដែលប្រចាំការទទួលពលករ ដែលបញ្ជូនត្រលប់ពីក្រៅប្រទេស នៅច្រកព្រំដែនអូរបីជាន់។<br>- បានដឹកនាំក្រុមការងារគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានសហការជាមួយអង្គការដៃគូអភិវឌ្ឍ អង្គការ UNFPA អង្គការ IOM ចុះទៅសំណេះសំណាល ស្តីពីការឆ្លើយតបនឹងវិបត្តិកូវីដ១៩ របស់សហគមន៍ និងចែកសម្ភារប្រើប្រាស់មួយចំនួនដល់ប្រជាពលរដ្ឋ៖<br>○ ចំនួន៥០គ្រួសារ នៅក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ចំនួន០១លើក។<br>○ ចំនួន១០០គ្រួសារ នៅស្រុកក្រឡាញ់ ខេត្តសៀមរាប ចំនួន០១លើក។<br>○ ចំនួន២០០គ្រួសារ នៅស្រុកមោងឫស្សី ខេត្តបាត់ដំបង ចំនួន០២លើក។<br>▪ លោកជំទាវវេជ្ជបណ្ឌិត ឧត្តមសេនីយ៍ឯក **ប៊ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញចូលរួមដឹកនាំកិច្ចប្រជុំផ្ទៃក្នុង ស្តីពីការបូកសរុបស្ថិតិប្រជាពលរដ្ឋដែលបានវិលត្រលប់មកពីក្រៅប្រទេស ចំនួន០១លើក និងស្តីពីផែនការសកម្មភាពជាតិឆ្នាំ២០២០ ចំនួន០៥លើក ដើម្បីដាក់ជូនក្រសួងមហាផ្ទៃ រៀបចំកម្មវិធីឆ្លងកិច្ចប្រជុំនេះ អ្នកចូលរួមចំនួន៥១នាក់ ស្រី១១នាក់។<br>▪ **លេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖**<br>- លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ ៤៩ច្បាប់ លិខិតចូល ១៦ច្បាប់។<br>- លិខិតរបស់ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ ៣២ច្បាប់ លិខិតចូល ៣៤ច្បាប់។ |

| | |
|---|---|
| | - រៀបចំកិច្ចប្រជុំ និងធ្វើកំណត់ហេតុ រាល់ពេលប្រជុំ។<br>- បូកសរុបរបាយការណ៍ប្រចាំសប្តាហ៍ និងខែមេសា ឧសភា និងខែមិថុនា ឆ្នាំ២០២០ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- បូកសរុបរបាយការណ៍ខែមេសា ឧសភា មិថុនា និងត្រីមាសទី២ ឆ្នាំ២០២០ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។<br>- ប្រមូលរបាយការណ៍ពីអន្តរក្រសួង ស្ថាប័ន និងរាជធានី/ខេត្តទាំង២៥។<br>- រៀបចំ និងបញ្ជូនលិខិតអញ្ជើញចូលរួមកិច្ចប្រជុំ ទៅកាន់ក្រសួង ស្ថាប័ន អង្គភាព រាជធានី-ខេត្ត និងអង្គការដៃគូពាក់ព័ន្ធនានា។<br>- ចងក្រងព័ត៌មាន រូបភាព និងសកម្មភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិចូលក្នុងបណ្ណាសារវីគី។<br>- ស្រាវជ្រាវព័ត៌មានពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ពីមជ្ឈដ្ឋានផ្សេងៗ ជាពិសេសព័ត៌មានដែលចុះផ្សាយ នៅក្នុងបណ្តាញសង្គម និងគេហទំព័រនានា។<br>- Scan & Uploaded ឯកសារចូលក្នុងបណ្ណាសារនៃប្រព័ន្ធ wiki បានចំនួន ៣២០ច្បាប់។<br>- អាប់ឡូតរូបភាពសកម្មភាព គ.ខ.ប.ជ ចូលបណ្ណាល័យរូបភាពក្នុងប្រព័ន្ធអ៊ិនធើណេត wiki បានចំនួន ៣៣សកម្មភាព។<br>▪ **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់**<br>- ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ និងតំណាងក្រសួងអប់រំ យុវជន និងកីឡា និងអង្គការដៃគូ បានបន្តរៀបចំតាក់តែងសៀវភៅសិក្សាគោល ស្តីពីការបង្ការ ទប់ស្កាត់ អំពើជួញដូរមនុស្ស និងសៀវភៅជំនួយវិធីសាស្ត្របង្រៀនសម្រាប់គ្រូ ចំនួន០២លើក នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- លោកប្រធានក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ បានដឹកនាំមន្ត្រីចូលរួមកិច្ចប្រជុំពិភាក្សាបង្កើតមេរៀនសៀវភៅសិក្សាគោល ស្តីពីការបង្ការ ទប់ស្កាត់ អំពើជួញដូរមនុស្ស និងសៀវភៅជំនួយវិធីសាស្ត្របង្រៀនសម្រាប់គ្រូ ចំនួន០២លើក ក្រោមអធិបតីភាព លោកជំទាវ **សឿ សុជាតា** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា នៅក្រសួងអប់រំ។<br>- លោកប្រធានក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ និងក្រុមការងារ បានចូលរួមប្រជុំពិភាក្សាបង្កើតសៀវភៅសិក្សា ស្តីពីការបង្ការ ទប់ស្កាត់ អំពើជួញដូរមនុស្ស និងសៀវភៅលំនាំគ្រូបង្រៀនបន្ត ចំនួន០២លើក នៅសាលប្រជុំនាយកដ្ឋាននីតិកម្ម ក្រសួងអប់រំ យុវជន និងកីឡា។<br>- ប្រធានក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ បានដឹកនាំក្រុមការងារ ចូលរួមប្រជុំរៀបចំគម្រោងសិក្ខាសាលា សម្រាប់ការចុះបណ្តុះបណ្តាលសាកល្បងលើសៀវភៅការអប់រំ និងលំនាំនៃការបង្រៀន ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ជូនដល់គ្រូឧទ្ទេសភូមិភាគ និងគរុសិស្សឆ្នាំទី២ ខេត្តកំពង់ចាម នៅសាលប្រជុំក្រសួងអប់រំ យុវជន និងកីឡា។<br>- ប្រធានក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ បានដឹកនាំក្រុមការងារចូលរួមសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ចុះផ្សព្វផ្សាយ និងបណ្តុះបណ្តាលសាកល្បងសៀវភៅអប់រំ និងលំនាំនៃការបង្រៀន ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ដើម្បីប្រមូលធាតុចូលបន្ថែម សម្រាប់កែលម្អការតាក់តែងសៀវភៅ និងផ្សព្វផ្សាយការងារប្រយុទ្ធប្រឆាំងជំងឺកូវីដ១៩ ជូនដល់គ្រូឧទ្ទេស និងគរុសិស្ស នៅខេត្តកំពង់ចាម។<br>- ប្រធានក្រុម និងមន្ត្រី០១រូប បានទៅចូលរួមប្រជុំពិភាក្សាកែសម្រួលអក្ខរាវិរុទ្ធ ខ្លឹមសារអត្ថបទ និងខ្លឹមសាររូបភាពសៀវភៅអប់រំ និងលំនាំនៃការបង្រៀន ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ថ្នាក់មធ្យមសិក្សា នៅសាលប្រជុំក្រសួងអប់រំ យុវជន និងកីឡា។<br>▪ **ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ** |

| | |
|---|---|
| | - លោកប្រធានក្រុមការងារ បានសហការជាមួយ UNFPA IOM និងភ្នាក់ងារដទៃទៀត បានចុះធ្វើការវាយតម្លៃអំពីផលប៉ះពាល់សង្គម និងសុខភាពដោយ ជំងឺកូវីដ១៩ លើពលករទេសន្តរប្រវេសន៍ ដែលបានវិលត្រឡប់មកវិញ នៅខេត្តចំនួន៣ (សៀមរាប បាត់ដំបង បន្ទាយមានជ័យ)។<br>- លោកប្រធានក្រុមការងារ បានចូលរួមកិច្ចប្រជុំបូកសរុបរបាយការណ៍ ឆមាសទី១ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រោមអធិបតីភាព ឯកឧត្តម **ញឹក វណ្ណារ៉ា** រដ្ឋលេខាធិការ ក្រសួងសង្គកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។<br>- លោកឧត្តមសេនីយ៍ទោ អគ្គលេខាធិការរង និងលោកប្រធានក្រុមការងារ បានសហការជាមួយ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអង្គការចាប់ដៃ បានចុះទទួលជនរងគ្រោះ នៅច្រកទ្វារអន្តរជាតិបាវិត ក្រុងបាវិត ខេត្តស្វាយរៀងចំនួន ០៣នាក់ ដែលអាជ្ញាធរវៀតណាមឃាត់ខ្លួន ដោយបានលួចរត់ឆ្លងមកពីប្រទេសចិន។<br>▪ **ក្រុមជំនួយកិច្ចការអនុវត្តច្បាប់**<br>- បានចូលរួមកិច្ចប្រជុំប្រមូលព័ត៌មានអំពីម្តាយ និងកូនស្រីដែលរងគ្រោះនៅប្រទេសចិន ហើយត្រូវបានជួយសង្គ្រោះត្រឡប់មកប្រទេសកម្ពុជាវិញ តាមច្រកប្រទេសវៀតណាម នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>▪ **ក្រុមជំនួយកិច្ចការយុត្តិធម៌**<br>- ឯកឧត្តម ឧត្តមសេនីយ៍ឯក អគ្គលេខាធិការរង បានអញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សារៀបចំសន្ទានុក្រមបច្ចេកទេពួក្នុងវិស័យសន្តិសុខ និងសណ្តាប់ធ្នាប់ នៃក្រសួងមហាផ្ទៃ ក្រោមអធិបតីភាព ឯកឧត្តម នាយឧត្តមសេនីយ៍សាស្ត្រាចារ្យ **សេង ផល្លី** ប្រធានបណ្ឌិតសភានគរបាលកម្ពុជា។<br>▪ **ក្រុមជំនួយកិច្ចសហប្រតិបត្តិការអន្តរជាតិ**<br>- លោកស្រី អនុប្រធានក្រុម បានចូលរួមជាមួយ ថ្នាក់ដឹកនាំក្រុមជំនួយកិច្ចការការពារជនរងគ្រោះ២រូប ផ្តល់កិច្ចសម្ភាសន៍តាមរយៈប្រព័ន្ធអ៊ីនធើណិត (SKYPE Video Conference) ក្នុងការស្រង់ទិន្នន័យសម្រាប់ការស្រាវជ្រាវ លើការអនុវត្ត "**គម្រោងផ្តល់វគ្គបណ្តុះបណ្តាលអំពីការសង្គ្រោះបឋមផ្នែកផ្លូវចិត្ត**" របស់អង្គការអន្តរជាតិសម្រាប់ទេសន្តរប្រវេសន៍ (IOM)។<br>- បានចូលរួមកិច្ចប្រជុំជាមួយ ប្រធានក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍ ជំនួយកិច្ចការការពារ ជនរងគ្រោះ និងជំនួយកិច្ចការអនុវត្តច្បាប់ ដើម្បីពិនិត្យផ្ទៀងផ្ទាត់និងដាក់បញ្ចូលចង្កោមសកម្មភាពរបស់ក្រុមជំនួយកិច្ចការនីមួយៗ តាមលេខរៀងដូចដើមទៅក្នុងផែនការសកម្មភាពឆ្នាំ២០២០ របស់អគ្គលេខាធិការដ្ឋាន នៅសាលប្រជុំអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ។<br>▪ **ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍**<br>- បានចូលរួមប្រជុំជាមួយ លោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ ដើម្បីជួយផ្តល់គំនិតត្រៀមឆ្លើយតបនូវសំនួរ៧ចំណុច ពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរបស់វិទ្យុស្ត្រី នៃមណ្ឌលព័ត៌មានស្ត្រីកម្ពុជា នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ |
| **លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន ៦៣លើក អ្នកចូលរួមសរុបចំនួន ១.៨៧៦នាក់ (ស្រី ៦៦០នាក់)** | |
| **ខេត្តកណ្តាល** | - គ.ខ.ប.ជ បានប្រជុំប្រចាំខែឧសភា និងឆមាសទី១ ឆ្នាំ២០២០ ចំនួន០២លើក អ្នកចូលរួមចំនួន១០៣នាក់ ស្រី៦១នាក់។<br>- ក្រុមការងារក្រុង-ស្រុក បានរៀបចំកិច្ចប្រជុំប្រចាំខែ ចំនួន៤១លើក អ្នកចូលរួមចំនួន៦៥១នាក់ ស្រី៣៨៦នាក់។ |

| | |
|---|---|
| ខេត្តសៀមរាប | - លេខាធិការដ្ឋាន គ.ខ.ប.ជ៖<br>○ បានរៀបចំកិច្ចប្រជុំប្រចាំខែមេសា ឧសភា ត្រីមាសទី១ និងប្រចាំឆមាសទី១ ឆ្នាំ២០២០ ចំនួន០៤លើក អ្នកចូលរួមចំនួន១១៩នាក់ ស្រី៣៧នាក់។<br>○ បានសហការជាមួយអង្គការសកម្មភាពដើម្បីកុមារ ប្រជុំពង្រឹងសមត្ថភាព ដល់សមាជិកលេខាធិការដ្ឋានថ្នាក់ខេត្ត ក្រុង ស្រុក ស្ដីពីការកើនកម្ពស់ការយល់ដឹង អំពីកិច្ចការបង្ការទប់ស្កាត់ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ តាមប្រព័ន្ធអ៊ិនធឺណេត និងរបៀបរាយការណ៍ប្រកបដោយសុវត្ថិភាព ចំនួន០១លើក អ្នកចូលរួមចំនួន ២៣នាក់ ស្រី១៧នាក់។<br>- ក្រុមការងារស្រុកបានប្រជុំ ចំនួន០៤លើក អ្នកចូលរួមចំនួន១០២នាក់ ស្រី៣៦នាក់។ |
| ខេត្តបាត់ដំបង | - ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្ត បានដឹកនាំប្រជុំបន្ទាន់ ស្ដីពីការទប់ស្កាត់ការលួចឆ្លងដែនខុសច្បាប់ ចំនួន០១លើក ដែលអ្នកចូលរួមមកពីបណ្ដាមន្ទីរ អង្គភាព ក្រុង ស្រុក និងយោធាវរសេនាតូចការពារព្រំដែនគោក នៅសាលាខេត្តបាត់ដំបង។ |
| ខេត្តកោះកុង | - គ.ខ.ប.ជ បានប្រជុំពិភាក្សាការងារជាមួយអង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី ស្ដីពីការលើកកម្ពស់សុវត្ថិភាព និងកិច្ចការពារដល់ពលករនេសាទនៅប្រទេសថៃ ទៅលើកិច្ចគាំទ្រសេវាកម្មផ្នែកច្បាប់ទាំងនៅក្នុងប្រទេស និងនៅប្រទេសថៃ នៅពេលដែលមានបញ្ហា អ្នកចូលរួមចំនួន១២នាក់ ស្រី០៥នាក់។<br>- ស្នងការដ្ឋាននគរបាលខេត្ត បានរៀបចំកម្មវិធីសំណេះសំណាលពង្រឹងសមត្ថភាពយេនឌ័រក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អ្នកចូលរួមចំនួ២២នាក់។ |
| ខេត្តស្វាយរៀង | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានប្រជុំឆ្លងរបាយការណ៍ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សប្រចាំឆមាសទី១ ឆ្នាំ២០២០ អ្នកចូលរួមចំនួន៥៧នាក់ ស្រី២៨នាក់។ |
| ខេត្តកំពង់ឆ្នាំង | - មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានដឹកនាំកិច្ចប្រជុំប្រចាំត្រីមាស របស់ក្រុមការងារការពារជនរងគ្រោះ ចំនួន០១លើក អ្នកចូលរួមចំនួន១៦នាក់ ស្រី០៤នាក់។ |
| ខេត្តកំពង់ធំ | - គ.ខ.ប.ជ បានប្រជុំប្រចាំខែ ឆ្នាំ២០២០ ចំនួន០៣លើក។ |
| ខេត្តកំពង់ចាម | - គ.ខ.ប.ជ បានប្រជុំប្រចាំខែឧសភា ឆ្នាំ២០២០ ចំនួន០១លើក<br>- គ.ខ.ប.ជ បានប្រជុំពិភាក្សាការងារជាមួយអង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី ស្ដីពីការលើកកម្ពស់សុវត្ថិភាព និងកិច្ចការពារដល់ពលករនេសាទនៅប្រទេសថៃ ទៅលើកិច្ចគាំទ្រសេវាកម្មផ្នែកច្បាប់ទាំងនៅក្នុងប្រទេស និងក្រៅប្រទេស នៅពេលដែលមានបញ្ហា អ្នកចូលរួមចំនួន១៣នាក់ ស្រី០៥នាក់។ |
| ខេត្តព្រៃវែង | - គ.ខ.ប.ជ បានប្រជុំពិភាក្សាការងារជាមួយអង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី ស្ដីពីការលើកកម្ពស់សុវត្ថិភាព និងកិច្ចការពារដល់ពលករនេសាទនៅប្រទេសថៃ ទៅលើកិច្ចគាំទ្រសេវាកម្មផ្នែកច្បាប់ទាំងនៅក្នុងប្រទេស និងក្រៅប្រទេស នៅពេលដែលមានបញ្ហា អ្នកចូលរួមចំនួន០៩នាក់ ស្រី០៤នាក់។ |
| ខេត្តតាកែវ | - បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើហិង្សាក្នុងគ្រួសារចំនួន០៣លើក អ្នកចូលរួមចំនួន២២៥នាក់ ស្រី១២នាក់។ |
| ខេត្តក្រចេះ | - លោកស្រីប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជខេត្ត បានដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សប្រចាំត្រីមាសទី១ និងទិសដៅបន្តខែមេសា ឆ្នាំ២០២០ អ្នកចូលរួម ៤២នាក់ ស្រី២១នាក់។ |
| ខេត្តឧត្តរមានជ័យ | - បានប្រជុំគណៈកម្មាធិការពិគ្រោះយោបល់លើកិច្ចការស្ត្រី និងកុមារចំនួន០១លើក អ្នកចូលរួមចំនួន៦០នាក ស្រី៣៨នាក់។ |